# សៀវភៅផ្តល់ព័ត៌មាន និងជម្រើសពីមធ្យោបាយពន្យារកំណើត

## សម្រាប់អ្នកផ្តល់សេវា









តារាងកូដព័ណ៌ គឺមានភាពងាយស្រួល និងឆាប់រហ័សសម្រាប់មើលការប្រៀបធៀបពីអត្ថប្រយោជន៍នៃមធ្យោបាយពន្យារកំណើតនីមួយៗ។

ជួយអតិថិជនក្នុងការស្វែងយល់ពីអត្ថប្រយោជន៍ នៃមធ្យោបាយពន្យារកំណើតនីមួយៗ។

សារគន្លឹះសំខាន់និងការណែនាំនៃជម្រើសមធ្យោបាយពន្យារកំណើត ដើម្បីបង្កើននូវការពេញចិត្ត និងការយល់ស្របរបស់អតិថិជន។

**សូមបញ្ជាក់ប្រាប់**
**អតិថិជនថា**
**អ្វីដែលគាត់ប្រាប់អ្នក**
**គឺរក្សាការសម្ងាត់**

psi Cambodia
Healthy lives. Measurable results.

| វិធីសាស្ត្រ |  មធ្យោបាយបញ្ឈប់កំណើត |  កងដាក់ក្រោមស្បែក |  កងដាក់ក្នុងស្បូន |  ថ្នាំចាក់ពន្យារកំណើត |  ថ្នាំគ្រាប់ពន្យារកំណើត |  ស្រោមអនាម័យ |  ថ្នាំគ្រាប់ការពារកំណើតបន្ទាន់ |
|---|---|---|---|---|---|---|---|
| ការពារការមានផ្ទៃពោះ | ✔ | ✔ | ✔ | ✔ | ✓ | ✓ | ✓ |
| មានផ្ទៃពោះវិញបន្ទាប់ពីឈប់ប្រើ | ✗ | ✔ | ✔ | ✓ | ✔ | ✔ | ✔ |
| ភាពជាឯកជន | ✔ | ✓ | ✓ | ✔ | ✓ | ✗ | ✔ |
| ការពារការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ | ✗ | ✗ | ✗ | ✗ | ✗ | ✔ | ✗ |
| មានផលរំខានតិចតួច | ✔ | ✓ | ✔ | ✗ | ✓ | ✔ | ✓ |
| មានរដូវតិច | ✗ | ✓ | ✗ | ✓ | ✔ | ✗ | ✗ |
| ងាយស្រួលប្រើ | ✔ | ✔ | ✔ | ✓ | ✗ | ✗ | ✓ |
| ងាយស្រួលចាប់ផ្តើម និងឈប់ប្រើ | ✗ | ✓ | ✓ | ✓ | ✔ | ✔ | ✔ |
| ចំណាយថវិកាតិច | ✔ | ✔ | ✔ | ✓ | ✓ | ✓ | ✗ |

| គន្លឹះ: | ✔ | ល្អណាស់សម្រាប់អ្នកដែលចង់បាន | ✓ | ល្អសម្រាប់អ្នកដែលចង់បាន | ✗ | មិនល្អសម្រាប់អ្នកដែលចង់បាន |
|---|---|---|---|---|---|---|

| | |
|---|---|
| **ស្វាគមន៍** | • សួស្តី ខ្ញុំឈ្មោះ ..... តើអ្នកឈ្មោះអ្វី ?<br>• អ្វីៗដែលអ្នកបានប្រាប់ខ្ញុំ នឹងត្រូវបានរក្សាការសម្ងាត់ |
| **ការសាកសួរ** | • តើអ្នកមានការអ្វីថ្ងៃនេះ ?<br>• តើអ្នកធ្លាប់មានបទពិសោធន៍ក្នុងការប្រើមធ្យោបាយពន្យារកំណើតដែរឬទេ ?<br>• តើអ្វីជាក្តីព្រួយបារម្ភរបស់អ្នក ?<br>• តើអ្នកមានបានគិតថា ចូលចិត្តមធ្យោបាយពន្យារកំណើតណាមួយក្នុងចិត្តហើយឬនៅ ? |
| **ការនិយាយប្រាប់** | • ការផ្លាស់ប្តូរឈាមរដូវ គឺធម្មតា ( ធម្មតា ឱកាស វិលត្រឡប់ មធ្យោបាយ បាត់រដូវ កំណត់: NORMAL )។<br>• និយាយប្រាប់អតិថិជនពីមធ្យោបាយពន្យារកំណើត២ទៅ៣មុខ ដែលឆ្លើយតបនឹងតម្រូវការ ឬ បញ្ជាក់បន្ថែមពីមធ្យោបាយ ដែលអតិថិជនបានគិតចង់ប្រើក្នុងចិត្តហើយ។ |
| **ការជួយ** | • ជួយធ្វើការប្រៀបធៀបមធ្យោបាយពន្យារកំណើត ២ ទៅ ៣ មុខតាមដែលអាចធ្វើទៅបាន ឬបញ្ជាក់បន្ថែមពីមធ្យោបាយ ដែលអតិថិជនបានជ្រើសរើសថា ប្រើក្នុងចិត្តហើយ។<br>• វាយតម្លៃសាកសួរ និងពិនិត្យលក្ខខ័ណ្ឌវេជ្ជសាស្ត្រអតិថិជន សម្រាប់មធ្យោបាយពន្យារកំណើតដែលបានជ្រើសរើស។<br>• សូមឲ្យនាងសម្រេចចិត្តជ្រើសរើសមធ្យោបាយណាមួយ ដែលសមស្របសម្រាប់នាង។ |
| **ការពន្យល់** | • ពន្យល់អំពី (3W) ចំណុចពីមធ្យោបាយពន្យារកំណើតដែល នាងជ្រើសរើស និងឲ្យនាងនិយាយសារឡើងវិញ។<br>• ធ្វើផែនការជាមួយគ្នាសម្រាប់របៀបប្រើ និងអ្វីដែលត្រូវធ្វើ ប្រសិនបើមានផលរំខានកើតមានឡើង។ |
| **ការវិលត្រឡប់** | • ត្រឡប់មកវិញគ្រប់ពេល បើអ្នកមានសំណួរ ឬកង្វល់។ |

| គន្លឹះ: | |
|---|---|
| ✓ (បៃតង) | ល្អណាស់សម្រាប់អ្នកដែលចង់បាន |
| ✓ (លឿង) | ល្អសម្រាប់អ្នកដែលចង់បាន |
| X | មិនល្អសម្រាប់អ្នកដែលចង់បាន |

ធម្មតា ឱកាស វិលត្រឡប់ មធ្យោបាយ បាត់រដូវ កំណត់: NORMAL

**ធម្មតា** (N ormal)

**ឱកាស** (O pportunities)

**វិលត្រឡប់** (R eturn)

**មធ្យោបាយ** (M ethods)

**បាត់រដូវ** (A bsence of period)

**កំណត់** ( L imit)

# ការពារការមានផ្ទៃពោះ

មានប្រសិទ្ធភាពជាង




ប្រសិទ្ធភាពតិចជាង

# មានផ្ទៃពោះវិញ បន្ទាប់ពីឈប់ប្រើ

## ការការពារការមានផ្ទៃពោះ

គ្រប់មធ្យោបាយពន្យារកំណើតទាំងអស់ការពារការមានផ្ទៃពោះបាន ការពារការរំលូតកូនដោយគ្មានសុវត្ថិភាព និងផលវិបាកពីការមានផ្ទៃពោះដែលមិនចង់បាន។

ជួយកាត់បន្ថយការប្រឈមមុខនឹងជំងឺមហារីកដែលជាមូលហេតុមិនអាចធ្វើឲ្យមានផ្ទៃពោះបាន។





ការពារការឆ្លងជំងឺកាមរោគដែលជាមូលហេតុមិនអាចធ្វើឲ្យមានផ្ទៃពោះបាន។



## ភាពត្រឡប់មកមានផ្ទៃពោះវិញ



# ភាពឯកជន

# ការពារការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ

មិនមានអ្នកដឹង តែអ្នកផ្តល់សេវាដឹង



ដៃគូអាចមានអារម្មណ៍ប៉ះខ្សែ តែអត់មានអ្នកណានឹងដឹង



អ្នកខ្លះអាចស្គាល់បើសិនជាដឹងកន្លែងដែលត្រូវស្វាប



អ្នកខ្លះអាចឃើញកញ្ចប់ថ្នាំ



អ្នកខ្លះមើលឃើញ និងមានការសហការពីដៃគូ



ផ្តល់នូវការការពារការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគផ្សេងទៀត



មិនអាចការពារការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ។ អ្នកត្រូវប្រើប្រូមជាមួយនឹងស្រោមអនាម័យ ប្រសិនបើអ្នកចង់ការពារខ្លួនពីការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ។



មិនអាចការពារការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ ប្រសិនបើដៃគូរបស់អ្នកមានផ្ទុកមេរោគអេដស៍ អ្នកអាចមានការប្រឈមមុខខ្ពស់ក្នុងការក្លាយជាអ្នកផ្ទុកមេរោគអេដស៍។ សំខាន់ណាស់ត្រូវប្រើប្រូមជាមួយនឹងស្រោមអនាម័យ។



# មានផលរំខានតិចតួច







- គ្មាន



- ប្រែប្រួលរដូវ។ នៅក្នុងពេលកំពុងដាក់កង ស្ត្រីខ្លះមានបទពិសោធន៍ឈឺពោះ។



- ប្រែប្រួលរដូវ ។ អ្នកប្រើខ្លះប្រាប់ពីផលរំខានមានដូចជា ឈឺក្បាល ឈឺពោះ ដោះឡើងតឹង។ ជារឿយៗផលរំខានបាត់ទៅវិញនៅក្នុងកំឡុងពេលណាមួយ។




- អ្នកប្រើខ្លះអាចជួបផលរំខានដូចជា ឈឺក្បាល វិលមុខ ដោះឡើងតឹង ប្រែប្រួលអារម្មណ៍។ ជារឿយៗផលរំខានបាត់ទៅវិញនៅក្នុងកំឡុងពេលណាមួយ។




- អាចបណ្តាលឲ្យឈឺក្រពះនិងក្អួត។ ផលរំខានទាំងអស់នឹងបាត់ទៅវិញកំឡុងពេល២៤ម៉ោង ក្រោយពេលលេបថ្នាំការពារកំណើតបន្ទាន់។ រដូវប្រហែលជាអាចមកលឿន ឬយឺត និងមានធ្លាក់ឈាមតិចៗចន្លោះរដូវ។



- ប្រែប្រួលរដូវ។ អ្នកប្រើខ្លះឡើងទំងន់ ឈឺក្បាល និងវិលមុខ។

# មានរដូវតិច

មធ្យោបាយពន្យារកំណើតភាគច្រើន គឺធ្វើឲ្យរដូវមានការប្រែប្រួល សូមពិនិត្យមើល **NORMAL** នៅទំព័របន្ទាប់ទៀត។ ការផ្លាស់ប្តូរគឺ វាខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ការរៀបរាប់នេះតែងតែជួបប្រទះចំពោះមធ្យោបាយពន្យារកំណើតនីមួយៗ។ បទពិសោធន៍នៃការផ្លាស់ប្តូរ វាមានភាពខុសគ្នាដូចដែលបានរៀបរាប់ដូចខាងក្រោមនេះ មិនមែនមានន័យថា មធ្យោបាយពន្យារកំណើតមិនមានប្រសិទ្ធភាពនោះទេ។

មិនមានរដូវ

## មានរដូវដូចការរំពឹងទុក



- ពីដំបូងអ្នកប្រើបាស់ខ្លះ អាចនឹងមានធ្លាក់ឈាមតិចៗ ចន្លោះរដូវ បន្ទាប់មកឈឺពោះតិចៗ។ ប្រសិនបើប្រើថ្នាំគ្រាប់បានត្រឹមត្រូវ និងទៀងទាត់នោះ អាចមានរដូវដូចការរំពឹងទុក។

មិនមាន ការប្រែប្រួល







- អ្នកប្រើប្រាស់ខ្លះមានរដូវច្រើនជាងមុនបន្តិចជាមួយនឹងការឈឺពោះ  ជាពិសេសនៅពេលប្រើរយៈពេល២ទៅ៣ខែដំបូង។

រដូវច្រើនជាងមុន

មិនមានរដូវ

## មករដូវមិនដូចការរំពឹងទុក



- ជាដំបូងអ្នកប្រើភាគច្រើនមករដូវមិនដូចការរំពឹងទុក និងពេលខ្លះយូរថ្ងៃ។ បន្ទាប់មកអ្នកប្រើប្រាស់ភាគច្រើនគឺគ្មានរដូវ និងឈឺពោះតិចៗ។



- អ្នកប្រើភាគច្រើនមានធ្លាក់ឈាមតិចៗចន្លោះរដូវ ឈឺពោះតិចៗ និងមករដូវមិនដូចការរំពឹងទុក។ អ្នកប្រើខ្លះមិនមានរដូវ។ បន្ទាប់មកលទ្ធភាពនៃការមិនមានរដូវកើនឡើង។



- បន្ទាប់ពីលេបថ្នាំគ្រាប់ការពារកំណើតបន្ទាន់ ឈាមរដូវអាចធ្លាក់ឆាប់ ឬយឺត និងមានធ្លាក់ឈាមតិចៗចន្លោះរដូវ។ ការប្រើថ្នាំគ្រាប់ការពារកំណើតបន្ទាន់ច្រើនអាចជាមូលហេតុឲ្យមានរដូវមិនដូចការរំពឹងទុក។

គ្មានការផ្លាស់ប្តូរ

# សារគន្លឹះត្រូវប្រាប់អតិថិជនដែលប្រើ មធ្យោបាយពន្យារកំណើតដែលមានជាតិអ័រម៉ូន

## ប្រែប្រួលការមករដូវ គឺ NORMAL



ស្ត្រីភាគច្រើនមានការយល់ច្រឡំពីការប្រែប្រួលរដូវនៅពេលប្រើមធ្យោបាយពន្យារកំណើតដែលមានជាតិអ័រម៉ូន។ ប្រើឧបករណ៍នេះ ជួយឲ្យអតិថិជនបានស្វែងយល់ពីការប្រែប្រួលការមករដូវ នៅពេលដែលពួកគេប្រើមធ្យោបាយពន្យារកំណើតដែលមានជាតិអ័រម៉ូន(១) គឺ NORMAL។ ផ្តល់ព័ត៌មានភ្ជាប់ជាមួយភស្តុតាងអំពីមធ្យោបាយជាក់លាក់ណាមួយដែលធ្វើឲ្យប្រែប្រួលការមករដូវ។ បន្ថែមលើនោះទៀត ការផ្តល់ប្រឹក្សាយោបល់នីមួយៗ ត្រូវប្រាប់ពីការប្រែប្រួលការមករដូវ និងពិភាក្សាពីអត្ថប្រយោជន៍ពីការកាត់បន្ថយការមករដូវ និងការឈឺចាប់។ សូមប្រើពាក្យ NORMAL ដើម្បីដោះស្រាយចំណុចទាំងអស់នេះជាមួយពួកគាត់។

**N** — **NORMAL** (ធម្មតា)៖ ប្រែប្រួលការមករដូវរបស់អ្នក គឺធម្មតា ពេលដែលអ្នកប្រើមធ្យោបាយពន្យារកំណើត។ រដូវអាចមកច្រើន ឬតិចជាងមុន។ ពេលខ្លះរដូវមិនដូចការំពឹងទុក ឬពេលខ្លះមិនមានរដូវតែម្តង។ ការប្រែប្រួលបែបនេះ វានឹងខុសគ្នាពី១ខែ ទៅ១ខែ (២)។

**O** — **OPPORTUNITIES** (ឱកាស)៖ ការមករដូវតិច ឬគ្មានអាចផ្តល់អត្ថប្រយោជន៍ដល់សុខភាព និងជីវិតផ្ទាល់ខ្លួនរបស់ស្ត្រី។

**R** — **RETURN** (ត្រឡប់)៖ ពេលដែលអ្នកឈប់ប្រើមធ្យោបាយពន្យារកំណើត រដូវរបស់អ្នកនឹងត្រឡប់មកដូចដើមវិញ ហើយក៏ជាឱកាសនៃការត្រឡប់ទៅការមានផ្ទៃពោះឡើងវិញ (៣)។

**M** — **METHODS** (វិធីសាស្ត្រ)៖ មធ្យោបាយពន្យារកំណើតផ្សេងទៀត អាចឲ្យមានការប្រែប្រួលរដូវផ្សេងគ្នាដែរ។ សូមឲ្យអ្នកផ្តល់សេវាប្រាប់អ្នកពីប្រភេទនៃការប្រែប្រួលរដូវដែលអ្នកអាចទទួលយកបាន។

**A** — **ABSENCE OF MENSES** (មិនមានរដូវ)៖ ៖ ការមិនមានរដូវមិនមែនមានន័យថា អ្នកមានផ្ទៃពោះទេ។ ប្រសិនជាអ្នកមានសញ្ញាថាមានផ្ទៃពោះសូមជួបអ្នកផ្តល់ប្រឹក្សា ឬប្រើឧបករណ៍ពិនិត្យទឹកនោម(៤)។

**L** — **LIMIT** (កម្រិត)៖ ប្រសិនបើការប្រែប្រួលរដូវនៅមានកម្រិត គឺមានវិធីសាស្ត្រសាមញ្ញក្នុងការព្យាបាល ។ សូមប្រាប់អ្នកផ្តល់សេវាពីរឿងនេះ។

[១].សារគន្លឹះដែលមាននៅក្នុងគោលការណ៍ណែនាំនេះ គឺទាក់ទងនឹងការប្រើប្រាស់មធ្យោបាយពន្យារកំណើតដែលមានជាតិអ័រម៉ូន។ សារគន្លឹះនេះ មិនចាំបាច់ប្រើជាមួយស្ត្រីដែលបានជ្រើសរើសមធ្យោបាយកងដាក់ក្នុងស្បូន។ [២].បន្ថែមលើចំណុចទាំងអស់នេះ សូមផ្តល់ព័ត៌មានអំពីវិធីសាស្ត្រ និងព័ត៌មានជាក់លាក់នៃការប្រែប្រួលរដូវ ទាំងមុននិងក្រោយពេលដែលស្ត្រីជ្រើសរើសមធ្យោបាយពន្យារកំណើត។ [៣].ប្រសិនបើអាច សូមផ្តល់ព័ត៌មានទៅដល់ស្ត្រីថា ពេលដែលប្រើថ្នាំចាក់ពន្យារកំណើត(ឧទាហរណ៍: DMPA) អាចពន្យារពេលក្នុងការត្រឡប់ទៅមានផ្ទៃពោះវិញ ប៉ុន្តែសម្រាប់មធ្យោបាយពន្យារកំណើតផ្សេងទៀតអាចនឹងមានកូនវិញភ្លាមបន្ទាប់ពីឈប់ប្រើ។ [៤].ប្រសិនបើអាច សូមផ្តល់ព័ត៌មាន ទៅដល់ស្ត្រីដែលកំពុងប្រើប្រាស់ថ្នាំគ្រាប់ពន្យារកំណើតឲ្យបានដឹងថា ការមិនមករដូវជាសញ្ញានៃការមានផ្ទៃពោះ។ ការមិនមករដូវនៅខែដំបូង នៃការប្រើកងក្រោមស្បែក ឬថ្នាំចាក់ពន្យារកំណើត គឺជាសញ្ញានៃការមានផ្ទៃពោះ។ ប្រាប់អតិថិជនរបស់អ្នកឱ្យត្រឡប់ទៅគ្លីនិកវិញ ប្រសិនបើគាត់មិនច្បាស់អំពីការមានផ្ទៃពោះ។

Developed in collaboration with FHI 360

# ងាយស្រួលប្រើ / ចាប់ផ្តើម / ឈប់ប្រើ

## ងាយស្រួលប្រើ

ជួបអ្នកផ្តល់សេវា ១ ឬ ២ ដង



ជួបអ្នកផ្តល់សេវា ជារៀងរាល់១ខែ ទៅ ៣ខែ



ប្រើរាល់ពេលរួមភេទ



ប្រើរៀងរាល់ថ្ងៃ



## ងាយស្រួលចាប់ផ្តើម / ឈប់ប្រើ

អាចរកបាននៅឱសថស្ថាន/ អ្នកផ្សព្វផ្សាយតាមសហគមន៍ និងឈប់ប្រើបានគ្រប់ពេលវេលា



ផ្តល់ដោយអ្នកផ្តល់សេវា បើចង់ឈប់ប្រើនៅពេលណា ត្រូវត្រឡប់ទៅកន្លែងទទួលសេវាវិញ





ផ្តល់ដោយអ្នកផ្តល់សេវា។ ឈប់បានរយៈពេល៣ខែ ចុងក្រោយបន្ទាប់ពីការចាក់ថ្នាំ



ជួបអ្នកផ្តល់សេវានៅពេលចាប់ផ្តើមប្រើ។ មិនអាចស្រាយ និងតភ្ជាប់ដូចដើមវិញ។

# ចំណាយថវិកាតិច

## ភាពញឹកញាប់នៃការចំណាយ

ម្តង



ពីរដង (ពេលដាក់ និងដក)



រៀងរាល់ ១ ទៅ ៣ខែ



រៀងរាល់ពេលរួមភេទ




គណនាជាមួយគ្នាអំពីការ
ចំណាយធៀបនឹងពេលវេលា
និង អាស្រ័យលើរយៈពេល
ដែលអ្នកចង់បានការការពារ។

សូមពិចារណាទាំងអស់គ្នា
ពីពេលវេលា និងការចំណាយ
សម្រាប់ធ្វើដំណើរទៅជួប
គ្រូពេទ្យម្តងៗ។

# មធ្យោបាយបញ្ឈប់កំណើត



| | |
|---|---|
| ល្អណាស់សម្រាប់អ្នកដែលចង់បាន៖ | នឹងគ្មានកូនជាងរៀងរហូត<br>ងាយស្រួលប្រើ<br>ភាពជាឯកជន<br>ចំណាយថវិកាតិចតួច<br>មានផលរំខានតិចតួច |
| មិនល្អសម្រាប់អ្នកដែលចង់បាន៖ | ត្រឡប់មកមានកូនវិញ (មិនអាចស្រាយ និងតភ្ជាប់ឲ្យដូចដើមវិញ)<br>ងាយស្រួលចាប់ផ្តើម/ឈប់ប្រើ<br>មានរដូចតិច<br>ការពារការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ |




| | |
|---|---|
| ជាជម្រើសល្អណាស់ប្រសិនបើអ្នក ៖ | បញ្ឈប់ការមានកូន |
| មិនល្អសម្រាប់អ្នកប្រសិនបើ៖ | ចង់បានកូនបន្ថែមទៀតនៅពេលអនាគត |

# មធ្យោបាយបញ្ឈប់កំណើត

## សារគន្លឹះសំខាន់មុនពេលជ្រើសរើស៖

- អាចប្រើបានទាំងបុរស ឬ ស្ត្រី។
- អ្នកផ្តល់សេវានឹងប្រើប្រាស់ថ្នាំស្ពឹក ដូច្នេះអ្នកនឹងមិនមានការឈឺចាប់កំឡុងពេលដំណើរការ។
- មិនមានការផ្លាស់ប្តូរសមត្ថភាពផ្លូវភេទរបស់អ្នក។
- មធ្យោបាយបញ្ឈប់កំណើត មិនអាចត្រឡប់មកមានផ្ទៃពោះវិញទេ។ អ្នកអាចប្រើប្រសិនបើប្រាកដថា មិនចង់បានកូនទៀតទេ។

ប្រសិនបើស្ត្រីចង់បានមធ្យោបាយបញ្ឈប់កំណើត
ធ្វើការបញ្ជូនទៅមន្ទីរពេទ្យដែលមានសេវានេះ

# កងដាក់ក្រោមស្បែក



| | |
|---|---|
| ល្អណាស់សម្រាប់អ្នកដែលចង់បាន៖ | ១ដើមការពារមិនឲ្យមានផ្ទៃពោះបានរហូតដល់៣ឆ្នាំ<br>២ដើមការពារមិនឲ្យមានផ្ទៃពោះបានរហូតដល់៥ឆ្នាំ<br>អាចមានកូនក្រោយពីដកកងក្រោមស្បែកចេញ<br>ងាយស្រួលប្រើ<br>ចំណាយថវិកាតិចតួច |
| ល្អសម្រាប់អ្នកដែលចង់បាន៖ | ភាពជាឯកជន<br>ងាយស្រួលចាប់ផ្តើម / ឈប់ប្រើ<br>មានរដូវតិច<br>មានផលរំខានតិចតួច |
| មិនល្អសម្រាប់អ្នកដែលចង់បាន៖ | ការពារការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ |

កងដាក់ក្រោមស្បែកធ្វើឲ្យខ្ញុំ អស់ក្តីបារម្ភ!



| | |
|---|---|
| ជាជម្រើសល្អណាស់ប្រសិនបើអ្នក៖ | ចង់រស់នៅដោយសេរី ដោយមិនចាំបាច់ចងចាំនូវការប្រើរៀងរាល់ថ្ងៃ |
| មិនល្អសម្រាប់អ្នកប្រសិនបើ៖ | មានរដូវទៀងទាត់ដូចការរំពឹងទុកដែលមានសារៈសំខាន់សម្រាប់អ្នក |

# កងដាក់ក្រោមស្បែក

## សារគន្លឹះសំខាន់មុនពេលជ្រើសរើស៖

- ✓ អ្នកផ្តល់សេវានឹងធ្វើឲ្យស្ពឹកនៅត្រង់កន្លែងដែលត្រូវដាក់បញ្ចូលកង ក្រោមស្បែក បន្ទាប់មកបញ្ចូលកងចូលទៅក្រោមស្បែកនៃដើមដៃរបស់អ្នករយៈពេល២ទៅ៣នាទី។
- ✓ អ្នកអាចត្រឡប់មកវិញ ប្រសិនបើចង់ដកកងក្រោមស្បែកចេញនៅពេលណាក៏បាន ជាមួយហេតុផលអ្វីក៏ដោយ។ អាចមានកូនក្រោយពីដកកងក្រោមស្បែកចេញ។
- ✓ រំលឹកឡើងវិញ **NORMAL**

*ប្រសិនបើស្ត្រីកំពុងប្រើឱសថប្រឆាំងមេរោគអេដស៍ efavirenz or nevirapine ប្រាប់ឲ្យនាងដឹងអំពីអន្តរកម្មថ្នាំ ដែលអាចមាន និងការកាត់បន្ថយតិចតួចនៃប្រសិទ្ធភាពពន្យារកំណើត។*

**3Ws:** ឲ្យអតិថិជននិយាយសារឡើងវិញមុនពេលចេញទៅផ្ទះ

| | |
|---|---|
| តើអ្វីដែលត្រូវធ្វើ ? | • ប្រើស្រោមអនាម័យ៧ថ្ងៃ ប្រសិនបើគាត់មិនបានដាក់កងក្រោមស្បែកក្នុងចន្លោះពីថ្ងៃទី១ ដល់ទី៧ នៃវដ្តឈាមរដូវ<br>• ថែរក្សាដៃដែលដាក់កងឲ្យស្អាត និងស្ងួតរហូតដល់ជាសះស្បើយ<br>• ជៀសវាងការលើករបស់ធ្ងន់ៗដោយដៃដែលដាក់កងក្នុងរយៈពេល២ថ្ងៃ |
| អ្វីខ្លះដែលរំពឹងទុកថានឹងអាចកើតមានឡើង | • ប្រែប្រួលវគ្គឈាមរដូវ អាចមានឈាមរដូវមិនទៀងទាត់ ពន្យារពេលវដ្តឈាមរដូវ អត់មានឈាមរដូវ |
| ពេលណាត្រូវត្រឡប់មកវិញ | • ពេលដែលអ្នកចង់សាកសួរសំណួរ មានការព្រួយបារម្ភ ឬចង់ផ្លាស់ប្តូរមធ្យោបាយពន្យារកំណើត<br>• គ្រប់ពេលដែលអ្នកចង់ដកកងចេញ<br>• ពី៣ ទៅ ៥ឆ្នាំ ដើម្បីដាក់កងក្រោមស្បែកថ្មីជំនួស |

**ការចងចាំ :**

- ✓ ប្រសិនបើមិនអាចកំណត់បានថាស្ត្រីអត់មានផ្ទៃពោះទេ ផ្តល់មធ្យោបាយពន្យារកំណើត និងណាត់ជួប៤សប្តាហ៍ក្រោយ
- ✓ ធ្វើការវាយតម្លៃសាកសួរ និងពិនិត្យល័ក្ខខ័ណ្ឌវេជ្ជសាស្ត្រអតិថិជន

**ការធ្វើផែនការ :**

- តើនាងនឹងគួរចងចាំរបៀបណាដើម្បីឲ្យដឹងថា ដល់ពេលមកប្តូរកងថ្មី ?
- តើនាងគួរធ្វើដូចម្តេចដើម្បីធានាថា បានរៀបចំសម្រាប់ការធ្លាក់ឈាមដែលមិន បានរំពឹងទុក

# កងដាក់ក្នុងស្បូន





<table>
<tr><td rowspan="5">ល្អណាស់សម្រាប់អ្នកដែលចង់បាន៖</td><td>ការពារមិនឲ្យមានផ្ទៃពោះរយៈពេល១០ឆ្នាំ</td></tr>
<tr><td>អាចមានកូនភ្លាមក្រោយដកកងចេញ</td></tr>
<tr><td>ងាយស្រួលប្រើ</td></tr>
<tr><td>ចំណាយថវិកាតិចតួច</td></tr>
<tr><td>មានផលរំខានតិចតួច</td></tr>
<tr><td rowspan="2">ល្អសម្រាប់អ្នកដែលចង់បាន៖</td><td>ភាពជាឯកជន</td></tr>
<tr><td>ងាយស្រួលចាប់ផ្តើម / ឈប់ប្រើ</td></tr>
<tr><td rowspan="2">មិនល្អសម្រាប់អ្នកដែលចង់បាន៖</td><td>ការពារការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ</td></tr>
<tr><td>មានរដូវតិច</td></tr>
</table>

កងដាក់ក្នុងស្បូន
ធ្វើឲ្យខ្ញុំមានអារម្មណ៍
ដូចធម្មជាតិ!



| | |
|---|---|
| ជាជម្រើសល្អណាស់ប្រសិនបើអ្នក៖ | ចង់បានរដូវមកទៀងទាត់ |
| មិនល្អសម្រាប់អ្នកប្រសិនបើ៖ | រដូវរបស់អ្នកច្រើន និងឈឺពោះ |

# កងដាក់ក្នុងស្បូន

## សារគន្លឹះសំខាន់មុនពេលជ្រើសរើស៖

- ✔ អ្នកផ្តល់សេវានឹងបញ្ចូលកងដាក់ក្នុងស្បូនទៅក្នុងស្បូនតាមរយៈទ្វារមាស។ អ្នកអាចមានអារម្មណ៍ឈឺពោះនៅក្នុងពេលដំណើរការ និងឈឺពោះពីរទៅបីថ្ងៃ បន្ទាប់ពីការដាក់កង។
- ✔ អ្នកអាចត្រឡប់មកវិញ ប្រសិនបើចង់ដកកងដាក់ក្នុងស្បូនចេញពេលណាក៏បានជាមួយហេតុផលអ្វីក៏ដោយ។ អាចមានកូនវិញភ្លាមបន្ទាប់ពីដកកងចេញ។

**3Ws:** ឲ្យអតិថិជននិយាយសារឡើងវិញមុនពេលចេញទៅផ្ទះ :

| | |
|---|---|
| តើអ្វីដែលត្រូវធ្វើ ? | • គ្មាន |
| អ្វីខ្លះដែលរំពឹងទុកថានឹងអាចកើតមានឡើង | • មានការឈឺចាប់តិចតួចក្នុងកំឡុងពេល២ ទៅ ៣ថ្ងៃ<br>• មានការប្រែប្រួលការធ្លាក់ឈាមរដូវ ពិសេសពី៣ទៅ៦ខែដំបូង<br>• អាចមានឈាមរដូវយូរ ឬមានឈាមរដូវមិនទៀងទាត់ឈាមរដូវនឹងមកទៀងទាត់វិញពេលក្រោយ មានឈាមរដូវច្រើនជាងមុន ឬឈឺចាប់ពេលមានឈាមរដូវ |
| ពេលណាត្រូវត្រឡប់មកវិញ | • ក្នុងកំឡុង៤ ទៅ ៦សប្តាហ៍ដើម្បីពិនិត្យតាមដាន<br>• ពេលដែលអ្នកចង់សាកសួរសំណួរ មានការព្រួយ បារម្ភ ឬចង់ផ្លាស់ប្តូរមធ្យោបាយពន្យារកំណើតផ្សេងទៀត<br>• គ្រប់ពេលដែលអ្នកចង់ដកកងចេញ<br>• ១០ ឆ្នាំ ដើម្បីដាក់កងថ្មីជំនួស<br>• បញ្ហាទាក់ទងនឹងការធ្លាក់ឈាមរដូវ<br>• ប្រសិនឈឺពោះផ្នែកខាងក្រោមខ្លាំងឡើងៗ ឬឈឺពេលរួមភេទ<br>• មានធ្លាក់សមិនធម្មតា<br>• មានគ្រុនក្តៅ ញាក់ ឬចង់ក្អួតចង្អោរ<br>• ប្រសិនអ្នកគិតថាអ្នកមានផ្ទៃពោះ ឬមានសញ្ញាសង្ស័យថាមានផ្ទៃពោះ<br>• មានបញ្ហាខ្សែកង បាត់ខ្សែកង ខ្សែកងវែងពេក ឬខ្លីពេក |

**ការចងចាំ :**

- ✔ ផ្ទៀងផ្ទាត់រកមើលការមានផ្ទៃពោះ
- ✔ ធ្វើការវាយតម្លៃសាកសួរ និងពិនិត្យលក្ខខណ្ឌវេជ្ជសាស្ត្រអតិថិជន

**ការធ្វើផែនការ :**

- តើនាងនឹងធ្វើដូចម្តេចប្រសិនបើមានការធ្លាក់ឈាមរដូវយូរ ?
- នាងត្រូវរៀបចំបែបណាសម្រាប់ការហូរឈាម មិនបានរំពឹងទុក ?

# ថ្នាំចាក់ពន្យារកំណើត





| | |
|---|---|
| ល្អណាស់សម្រាប់អ្នកដែលចង់បាន៖ | ការពារមិនឲ្យមានផ្ទៃពោះបាន៣ខែ (ចាក់រៀងរាល់៣ខែម្តង)<br>ភាពជាឯកជន |
| ល្អសម្រាប់អ្នកដែលចង់បាន៖ | មានផ្ទៃពោះវិញ បន្ទាប់ពីឈប់ប្រើ<br>ងាយស្រួលចាប់ផ្តើម / ឈប់ប្រើ<br>ចំណាយថវិកាតិច<br>មានរដូវតិច<br>មានផលរំខានតិចតួច |
| មិនល្អសម្រាប់អ្នកដែលចង់បាន៖ | ការពារការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ<br>មានផលរំខានតិច |

ថ្នាំចាក់ពន្យារកំណើត ជួយខ្ញុំរក្សាការសម្ងាត់!



| | |
|---|---|
| ជាជម្រើសល្អណាស់ ប្រសិនបើអ្នក៖ | មិនចង់ឲ្យអ្នកណាម្នាក់ដឹងថាអ្នកកំពុងប្រើថ្នាំចាក់ពន្យារកំណើត |
| មិនល្អសម្រាប់អ្នក ប្រសិនបើ៖ | អ្នកចង់មាន រដូវទៀងទាត់ ឬចង់មានផ្ទៃពោះ៦ខែក្រោយ |

# ថ្នាំចាក់ពន្យារកំណើត

## សារគន្លឹះសំខាន់មុនពេលជ្រើសរើស៖

- រំលឹកឡើងវិញ **NORMAL**
- អាចចំណាយពេលច្រើនខែបន្ថែមទៀតសម្រាប់ការមករដូវ និងត្រឡប់ទៅមានផ្ទៃពោះវិញបន្ទាប់ពីឈប់ប្រើថ្នាំចាក់។
- ប្រសិនបើដៃគូរបស់អ្នកមានផ្ទុកមេរោគអេដស៍ វិធីសាស្ត្រនេះនឹងបង្កើនការប្រឈមមុខខ្ពស់នៃការឆ្លងមេរោគអេដស៍។ ត្រូវប្រើស្រោមអនាម័យ បន្ថែមលើមធ្យោបាយនេះដើម្បីការពារការឆ្លងមេរោគអេដស៍។
- ប្រសិនបើអ្នកមានការយឺតយ៉ាវក្នុងការណាត់ជួបនៅបីខែបន្ទាប់ សូមប្រញាប់ត្រឡប់មកជួបតាមតែអាចធ្វើបាន អ្នកអាចនឹងចាក់ថ្នាំឡើងវិញ។

**3Ws:** ឲ្យអតិថិជននិយាយសារឡើងវិញមុនពេលចេញទៅផ្ទះ :

| | |
|---|---|
| តើអ្វីដែលត្រូវធ្វើ ? | • ប្រើស្រោមអនាម័យ៧ថ្ងៃប្រសិនបើគាត់មិនបានដាក់កងក្រោមស្បែកក្នុងចន្លោះពីថ្ងៃទី១ដល់ទី៧នៃវដ្តឈាមរដូវ។ |
| អ្វីខ្លះដែលរំពឹងទុកថានឹងអាចកើតមានឡើង | • មានការប្រែប្រួលការធ្លាក់ឈាមរដូវ អាចពន្យារពេលមកឈាមរដូវ មានឈាមរដូវមិនទៀងទាត់ ធ្លាក់ឈាមញឹកញាប់ បាត់ឈាមរដូវ<br>• ការមានរដូវ និងការវិលត្រឡប់មករកភាពមានកូនវិញ អាចមានរយៈពេលច្រើនខែក្រោយពីឈប់ចាក់ថ្នាំ |
| ពេលណាត្រូវត្រឡប់មកវិញ | • រៀងរាល់៣ខែម្តងដើម្បីចាក់ថ្នាំសារជាថ្មី (២ខែសម្រាប់ Net-En)<br>• ពេលដែលអ្នកចង់សាកសួរសំណួរ មានការព្រួយបារម្ភ ឬ ចង់ផ្លាស់ប្តូរមធ្យោបាយពន្យារកំណើតផ្សេងទៀត<br>• ប្រសិនបើអ្នកមានកើតឡើងបញ្ហាសុខភាព<br>• ប្រសិនបើអ្នកសង្ស័យថាមានផ្ទៃពោះ |

**ការចងចាំ :**

- ប្រសិនបើមិនអាចកំណត់បានថាស្ត្រីអត់មានផ្ទៃពោះទេ ផ្តល់មធ្យោបាយពន្យារកំណើតនិងធ្វើការណាត់ជួប៤សប្តាហ៍ក្រោយ
- ធ្វើការវាយតម្លៃ សាកសួរ និងពិនិត្យល័ក្ខខ័ណ្ឌវេជ្ជសាស្ត្រអតិថិជន

**ការធ្វើផែនការ :**

- តើនាងនឹងគួរចងចាំរបៀបណាដើម្បីឲ្យដឹងថាដល់ពេលមកចាក់ថ្នាំជាថ្មី ?
- តើនាងគួរធ្វើដូចម្តេចដើម្បីធានាថាបានរៀបចំសម្រាប់ការធ្លាក់ឈាមដែលមិនបានរំពឹងទុក

# ថ្នាំគ្រាប់ពន្យារកំណើត





| | |
|---|---|
| ល្អណាស់សម្រាប់អ្នកដែលចង់បាន៖ | មានកូនវិញបន្ទាប់ពីឈប់លេខ<br>ងាយស្រួលចាប់ផ្ដើម / ឈប់ប្រើ<br>មានរដូវតិច |
| ល្អសម្រាប់អ្នកដែលចង់បាន៖ | ការពារការមានផ្ទៃពោះបើប្រើត្រឹមត្រូវទៀងទាត់ពេលវេលា<br>ចំណាយថវិកាតិច<br>មានភាពឯកជន<br>មានផលរំខានតិចតួច |
| មិនល្អសម្រាប់អ្នកដែលចង់បាន៖ | ងាយស្រួលប្រើ<br>ការពារការឆ្លងមេរោគអេដស៍និងជំងឺកាមរោគ |

ថ្នាំគ្រាប់ពន្យារកំណើត ការពារខ្ញុំពីការមានផ្ទៃពោះ!



| | |
|---|---|
| ជាជម្រើសល្អណាស់ប្រសិនបើអ្នក៖ | ចង់បានរដូវតិច និងមកតាមការរំពឹងទុក |
| មិនល្អសម្រាប់អ្នកប្រសិនបើ៖ | ភ្លេចភ្លាំងច្រើន ឬ មិនចូលចិត្តការប្រើរៀងរាល់ថ្ងៃ |

# ថ្នាំគ្រាប់ពន្យារកំណើត

**3Ws:** ឲ្យអតិថិជននិយាយសារឡើងវិញមុនពេលចេញទៅផ្ទះ :

| | |
|---|---|
| តើអ្វីដែលត្រូវធ្វើ ? | • អ្នកត្រូវលេបថ្នាំគ្រាប់រៀងរាល់ថ្ងៃទៀងទាត់ដើម្បីឲ្យមានប្រសិទ្ធភាព ទោះបីជាអ្នកមិនបានរួមភេទក៏ដោយ។<br>• ប្រសិនបើអ្នកភ្លេចលេបថ្នាំមួយគ្រាប់ លេបមួយគ្រាប់វិញភ្លាមពេលនឹកឃើញ។<br>• ប្រសិនអ្នកភ្លេចលេបថ្នាំនេះ៣គ្រាប់ឡើងទៅក្នុងសប្តាហ៍ទី១ រួមទាំងចាប់ផ្តើមលេបបន្ទះថ្នាំថ្មីយឺតពេល ហើយគាត់បានរួមភេទក្នុងកំឡុង៥ថ្ងៃមុននោះ ស្ត្រីត្រូវលេបថ្នាំការពារកំណើតបន្ទាន់ និងប្រើស្រោមអនាម័យមួយសប្តាហ៍ (រំលឹកឡើងវិញអំពីស្រោមអនាម័យ និងថ្នាំគ្រាប់ការពារកំណើតបន្ទាន់)។<br>• ប្រសិនបើអ្នកភ្លេចលេបថ្នាំនេះ៣គាប្រ់ឡើងទៅនៅក្នុងសប្តាហ៍ទី៣ ស្ត្រីត្រូវរំលងជួរគ្រាប់ថ្នាំដែលគ្មានជាតិថ្នាំ ចាប់ផ្តើមលេបបន្ទះថ្មីនៅចុងសប្តាហ៍ទី៣។<br>• ប្រសិនស្ត្រីមិនបានចាប់ផ្តើមលេបថ្នាំគ្រាប់បន្ទះដំបូងកំឡុង៧ថ្ងៃនៃវដ្តឈាមរដូវ ត្រូវប្រើស្រោមអនាម័យរយៈពេល៧ថ្ងៃ។ |
| អ្វីខ្លះដែលរំពឹងទុកថានឹងអាចកើតមានឡើង | • ធ្លាក់ឈាមតិចតួចចន្លោះវដ្តឈាមរដូវ កើតមាន២ទៅ៣ខែដំបូង<br>• ផលរំខានផ្សេងទៀតដូចជា អាចឈឺក្បាលតិចតួច ចង់ក្អួត ឬចង្អោរ អាចបាត់ទៅវិញ២ទៅ៣ខែក្រោយ។ |
| ពេលណាត្រូវត្រឡប់មកវិញ | • មុនពេលលេបថ្នាំអស់ពីបន្ទះ ទៅយកបន្ទះថ្នាំថ្មីសម្រាប់លេបបន្ត<br>• ពេលដែលអ្នកចង់សាកសួរសំណួរ មានការព្រួយបារម្ភ ឬ ចង់ផ្លាស់ប្តូរមធ្យោបាយពន្យារកំណើតផ្សេងទៀត<br>• ប្រសិនបើអ្នកមានអារម្មណ៍ថា ACHES: ឈឺពោះឈឺទ្រូង ឈឺក្បាល បញ្ហាភ្នែក, ឈឺកំភួនជើងខ្លាំង<br>• ប្រសិនបើអ្នកសង្ស័យថាមានផ្ទៃពោះ |

## ការចងចាំ :

- ✔ ប្រសិនបើមិនអាចកំណត់បានថាស្ត្រីអត់មានផ្ទៃពោះទេ ផ្តល់មធ្យោបាយពន្យារកំណើត និងធ្វើការណាត់ជួប៤សប្តាហ៍ក្រោយ
- ✔ ធ្វើការវាយតម្លៃសាកសួរ និងពិនិត្យល័ក្ខខ័ណ្ឌវេជ្ជសាស្រ្តអតិថិជន

## ការធ្វើផែនការ :

- តើនាងនឹងគួរចងចាំរបៀបណាដើម្បីឲ្យដឹងថាលេបថ្នាំទៀងទាត់រៀងរាល់ថ្ងៃ ?
- តើនាងគួរទៅរកថ្នាំការពារកំណើតបន្ទាន់នៅទីណា ប្រសិនបើនាងភ្លេចលេបថ្នាំ

# ស្រោមអនាម័យ





| | |
|---|---|
| ល្អណាស់សម្រាប់អ្នកដែលចង់បាន៖ | ការពារការឆ្លងមេរោគអេដស៍និងជំងឺកាមរោគ<br>មានកូនវិញភ្លាមបន្ទាប់ពីឈប់ប្រើ<br>ងាយស្រួលចាប់ផ្តើម/ឈប់ប្រើ<br>មានផលរំខានតិច |
| ល្អសម្រាប់អ្នកដែលចង់បាន៖ | ការពារការមានផ្ទៃពោះបើប្រើត្រឹមត្រូវ<br>ចំណាយថវិកាតិច |
| មិនល្អសម្រាប់អ្នកដែលចង់បាន៖ | ដៃគូមិនចង់ប្រើ<br>ភាពជាឯកជន<br>មានរដូវតិច |

ស្រោមអនាម័យធ្វើឲ្យពួកយើងមានអារម្មណ៍ថាបានការពារខ្លួន!



| | |
|---|---|
| ជាជម្រើសល្អណាស់ប្រសិនបើអ្នក៖ | ចង់ការពារការឆ្លងមេរោគអេដស៍និងជំងឺកាមរោគផ្សេងទៀត |
| មិនល្អសម្រាប់អ្នកប្រសិនបើ៖ | ដៃគូរបស់អ្នកមិនប្រើជារៀងរាល់ពេលរួមភេទ-បន្ទាប់មកអ្នកត្រូវប្រើមធ្យោបាយបម្រុងណាមួយ |

# ស្រោមអនាម័យ

**3Ws:** ឲ្យអតិថិជននិយាយសារឡើងវិញមុនពេលចេញទៅផ្ទះ :

| | |
|---|---|
| តើអ្វីដែលត្រូវធ្វើ ? | • យកម្រាមដៃពីរច្របាច់ចុងស្រោមអនាម័យហើយរមៀលចុះក្រោមពីក្បាលលិង្គដែលឡើងរឹង<br>• ប្រើស្រោមអនាម័យថ្មីជានិច្ចរៀងរាល់ពេលរួមភេទ។<br>• ប្រើស្រោមអនាម័យតែមួយរាល់ពេលរួមភេទម្តង។<br>• ទឹករំអិលអាចការពារការរហែក ប៉ុន្តែទឹករំអិលដែលមានជាតិប្រេងអាចបំផ្លាញស្រោម។<br>• ប្រើថ្នាំការពារកំណើតបន្ទាន់ប្រសិនបើស្រោមរហែក ឬមិនបានប្រើវា។<br>• ឲ្យអតិថិជនអនុវត្តន៍ការពាក់ស្រោមអនាម័យលើលិង្គគំរូ។ |
| អ្វីខ្លះដែលរំពឹងទុកថានឹងអាចកើតមានឡើង | • គ្មានផលរំខាន |
| ពេលណាត្រូវត្រឡប់មកវិញ | • ប្រសិនបើអ្នកត្រូវការស្រោមទៀត<br>• ពេលដែលអ្នកចង់សាកសួរសំណួរ មានការព្រួយបារម្ភ ឬចង់ផ្លាស់ប្តូរមធ្យោបាយពន្យារកំណើតផ្សេងទៀត<br>• ប្រសិនបើអ្នកសង្ស័យថាមានផ្ទៃពោះ |

**ការចងចាំ :**

✔ ប្រសិនបើមិនអាចកំណត់បានថាស្ត្រីអត់មានផ្ទៃពោះទេ ផ្តល់មធ្យោបាយពន្យារកំណើត និងធ្វើការណាត់ជួប៤សប្តាហ៍ក្រោយ

**ការធ្វើផែនការ :**

- តើនាងនឹងគួរចរចាបែបណាជាមួយដៃគូក្នុងការប្រើស្រោមអនាម័យ ?
- តើនាងនឹងទុកស្រោមនៅកន្លែងណាដើម្បីងាយមានប្រើស្រាប់ពេលត្រូវការ ?

# ថ្នាំគ្រាប់ការពារកំណើតបន្ទាន់




| | |
|---|---|
| ល្អណាស់សម្រាប់អ្នកដែលចង់បាន៖ | មានផ្ទៃពោះវិញ បន្ទាប់ពីឈប់លេប<br>ភាពជាឯកជន<br>ងាយស្រួលចាប់ផ្តើម/ឈប់ប្រើ |
| ល្អសម្រាប់អ្នកដែលចង់បាន៖ | ការពារការមានផ្ទៃពោះ(ប្រសិនប្រើអំឡុង៧២ម៉ោងបន្ទាប់ពីរួមភេទដោយមិនបានការពារ)<br>ងាយស្រួលប្រើ<br>មានផលរំខានតិចតួច |
| មិនល្អសម្រាប់អ្នកដែលចង់បាន៖ | ការពារការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ<br>ចំណាយថវិកាតិច<br>មានរដូវតិច |

ថ្នាំគ្រាប់ការពារកំណើតបន្ទាន់ បានធ្វើឲ្យខ្ញុំមានអារម្មណ៍ថាធូរស្រាល!



| | |
|---|---|
| ជាជម្រើសល្អណាស់ប្រសិនបើអ្នក៖ | ប្រសិនបើអ្នករួមភេទដោយមិនបានការពារកំឡុងពេល៣ថ្ងៃ |
| មិនល្អសម្រាប់អ្នកប្រសិនបើ៖ | ជាបញ្ហាធំប្រសិនបើអ្នកកំពុងមានផ្ទៃពោះព្រោះមិនមានប្រសិទ្ធភាពដូចមធ្យោបាយផ្សេងទេ |

# ថ្នាំគ្រាប់ការពារកំណើតបន្ទាន់

## សារគន្លឹះសំខាន់មុនពេលជ្រើសរើស៖

- ✔ ថ្នាំគ្រាប់ការពារកំណើតបន្ទាន់មានប្រសិទ្ធភាពកំឡុងពេល៧២ម៉ោងបន្ទាប់ពីរួមភេទដោយមិនបានការពារ ប៉ុន្តែបើអ្នកប្រើវាកាន់តែឆាប់ នោះប្រសិទ្ធភាពវាកាន់តែខ្ពស់។
- ✔ ថ្នាំគ្រាប់ការពារកំណើតបន្ទាន់ មិនមែនជាឱសថសម្រាប់រំលូតកូននោះទេ។ វាមិនមានប្រសិទ្ធភាពទេប្រសិនបើអ្នកមានផ្ទៃពោះរួចទៅហើយ។ ថ្នាំនេះមិនបង្កគ្រោះថ្នាក់ដល់ទារកទេ។
- ✔ ការប្រើថ្នាំគ្រាប់ការពារកំណើតបន្ទាន់ញឹកញាប់ វានឹងមិនប៉ះពាល់ដល់សុខភាពទេ។ មិនមានបញ្ហាអ្វីទេនៅពេលដែលអ្នកប្រើច្រើនដងនៅកំឡុងពេលមួយវដ្តឈាមរដូវក៏ដោយ។ទោះយ៉ាងណាថ្នាំគ្រាប់ការពារកំណើតបន្ទាន់មានប្រសិទ្ធភាពទាបជាងមធ្យោបាយពន្យារកំណើតផ្សេងទៀត។
- ✔ ប្រសិនបើអ្នកប្រើថ្នាំគ្រាប់ការពារកំណើតបន្ទាន់ជាប្រចាំ សូមពិចារណាប្រើប្រាស់មធ្យោបាយពន្យារកំណើតផ្សេងទៀតដែលមានប្រសិទ្ធភាពនិងតម្លៃសមរម្យ។

**3Ws:** ឲ្យអតិថិជននិយាយសារឡើងវិញមុនពេលចេញទៅផ្ទះ :

| | |
|---|---|
| តើអ្វីដែលត្រូវធ្វើ ? | • លេបថ្នាំគ្រាប់ការពារកំណើតកូនបន្ទាន់ភ្លាមក្នុងកំឡុងពេល ៧២ម៉ោង ឬ៣ថ្ងៃបន្ទាប់ពីមានការរួមភេទដែលមិនបានការពារ។<br>• ប្រសិនបើអ្នកមានក្អួតក្នុងកំឡុងពេល២ម៉ោងបន្ទាប់ពីលេបថ្នាំ លេបថ្នាំមួយកំរិតដូសទៀត។ |
| អ្វីខ្លះដែលរំពឹងទុកថានឹងអាចកើតមានឡើង | • អាចក្អួតឬចង្អោរ<br>• អាចធ្លាក់ឈាមមិនទៀងទាត់ អាចធ្លាក់ឈាមរដូវមុន ឬយឺត |
| ពេលណាត្រូវត្រឡប់មកវិញ | • ពេលដែលអ្នកចង់សាកសួរសំណួរ មានការព្រួយបារម្ភ ឬ ចង់ផ្លាស់ប្តូរមធ្យោបាយពន្យារកំណើតផ្សេងទៀត។<br>• ប្រសិនបើអ្នកសង្ស័យថាមានផ្ទៃពោះ |

**ការចងចាំ :**

- ✔ កងដាក់ក្នុងស្បូនអាចប្រើជាមធ្យោបាយការពារកំណើតបន្ទាន់កំឡុង៧២ម៉ោង ឬលើសពីនេះ បន្ទាប់ពីមានការរួមភេទមិនបានការពារ មានប្រសិទ្ធភាពជាងថ្នាំគ្រាប់។

**ការធ្វើផែនការ :**

- តើនាងនឹងទុកថ្នាំគ្រាប់ការពារកំណើតកូននៅកន្លែងណាដើម្បីងាយមានប្រើស្រាប់ពេលត្រូវការ ?
- តើពេលណាដែលនាងអាចលេបថ្នាំការពារកំណើតបន្ទាន់ទៀត ?

# ស្ត្រីក្រោយសម្រាល បំបៅកូនដោយទឹកដោះម្ដាយ




**សំគាល់:** មធ្យោបាយបំបៅកូនដោយទឹកដោះម្ដាយគឺជាមធ្យោបាយមានប្រសិទ្ធភាពក្នុងកំឡុងពេល៦ខែដំបូងក្រោយសម្រាល ប្រសិនបើម្ដាយបំបៅកូនដោយទឹកដោះខ្លួនឯងតែមួយមុខគត់ (គ្មានបន្ថែមអាហារអ្វីក្រៅពីទឹកដោះម្ដាយ) ឲ្យបានញឹកញាប់ ទាំងយប់ទាំងថ្ងៃយ៉ាងតិច៨ដងក្នុង១ថ្ងៃ និងម្ដាយមិនទាន់មានឈាមរដូវក្រោយពេលសម្រាលកូនរួច។

# ក្រោយរំលូត



ចាប់ផ្ដើមប្រើដូចថ្ងៃដែលប្រើក្នុងផ្ទៃពោះត្រីមាសទី១ ឬទី២ ឬគ្រប់ពេល។



ចាប់ផ្ដើមប្រើដូចថ្ងៃដែលប្រើក្នុងផ្ទៃពោះត្រីមាសទី១ ឬទី២ មិនមានពេលដាក់លាក់ និងរំលូតស្អាតដោយការបូមសម្អាតស្បូនដោយប្រើឧបករណ៍បូមដោយដៃ ឬដោយប្រើឱថស និងការថែទាំការរំលូតមិនស្អាតដោយប្រើមីសូប្រូស្តុល។



**សម្រាប់ស្ត្រី**: ការចោះចងដៃស្បូនៈ ក្រោយរំលូតស្អាត អាចពន្យារពេល ប្រសិនបើមានការបង្ករោគ ធ្លាក់ឈាមខ្លាំង របួសស្បូន ឬ ឈាមហូរផ្ដុំក្នុងស្បូនស្រួចស្រាវ។

**សម្រាប់បុរស**: គ្រប់ពេល

## ពិធីសារជាតិស្តីពីការពន្យារកំណើតឆ្នាំ២០១៦ លក្ខខណ្ឌវេជ្ជសាស្ត្រសម្រាប់ប្រើថ្នាំគ្រាប់មានជាតិអ័រម៉ូនលាយគ្នា ស៊ី អូ ស៊ី

| | | សូមគូស (✓) ក្នុងប្រអប់ហើយធ្វើតាមការណែនាំពីដើមរហូតដល់ចប់ | ចាស | ទេ |
|---|---|---|---|---|
| បញ្ជីសំនួរ សំរាប់ ថ្នាំគ្រាប់ ពន្យារកំណើត OK®/EVAMarvelon (COC) | ១ | កំពុងកើតជំងឺថ្លើម (ស្បែក ភ្នែកលឿង) ឬ៦សប្តាហ៍មុន | | |
| | ២ | ដុំដោះខុសធម្មតា | | |
| | ៣ | អាយុ៣៥ឆ្នាំ ឬលើសពីនេះ និងជក់បារី | | |
| | ៤ | សរសៃឈាមខ្មៅ នៅជើងហើមរឹង | | |
| | ៥ | មានសំពាធឈាមលើសពី១៤០/៩០mmHg ឬលើសនេះ | | |
| | ៦ | ឈឺក្បាលខ្លាំង (ជំងឺប្រកាំង) | | |
| | ៧ | ជំងឺប្រើសបេះដូងធ្ងន់ធ្ងរ | | |
| | ៨ | កំពុងព្យាបាលដោយប្រើថ្នាំប្រឆាំងការប្រកាច់ ឬថ្នាំរបេង (Rifampicin) ឬ (Rifabutin) | | |
| | ៩ | ជំងឺថង់ប្រម៉ាត់ | | |
| | | បើឆ្លើយ (ចាស) នូវសំនួរណាមួយ ➜ ឈប់ | | |
| | | បើឆ្លើយ (ទេ) គ្រប់សំនួរទាំងអស់ ➜ ថ្នាំគ្រាប់ពន្យាកំណើត OK®/EVA Marvelon(COC) ត្រូវបានផ្តល់ជូនអតិថិជនបាន | | |

## ថ្នាំចាក់ (DMPA) កងដាក់ក្រោមស្បែកមានផ្ទុកអ័រម៉ូនប្រូសេស្ទីនតែមួយមុខគត់មធ្យោបាយកងដាក់ក្នុងស្បូន (TCu-IUD)

| | | | | |
|---|---|---|---|---|
| បញ្ជីសំណួរសំរាប់ ថ្នាំចាក់ពន្យារកំណើត OK® | ១ | កំពុងកើតជំងឺថ្លើម (ស្បែក ភ្នែកលឿង) ឬ៦សប្តាហ៍មុន | | |
| | ២ | ធ្លាប់មានឬកំពុងមានសរសៃឈាមខ្មៅឡើងប៉ោងរឹងនៅកំភួនជើង | | |
| | ៣ | ដុំដោះខុសធម្មតា | | |
| | ៤ | កំពុងប្រើថ្នាំប្រឆាំងការប្រកាច់ ឬថ្នាំ Rifampicin ឬ Rifantutin | | |
| | ៥ | មានសំពាធឈាមលើសពី១៦០/១០០mmHg | | |
| | ៦ | មានប្រវត្តិ ឬកំពុងមានជំងឺបេះដូង | | |
| | ៧ | ធ្លាក់ឈាមខុសធម្មតា | | |
| | | បើឆ្លើយ (ចាស) នូវសំនួរណាមួយ ➜ ឈប់ | | |
| | | បើឆ្លើយ (ទេ) គ្រប់សំណួរទាំងអស់ ➜ ថ្នាំគ្រាប់ពន្យាកំណើត OK®/EVA Marvelon(COC) ត្រូវបានផ្តល់ជូនអតិថិជនបាន | | |

| | | | សូមគូស (✓) ក្នុងប្រអប់ហើយធ្វើតាមការណែនាំពីដើមរហូតដល់ចប់ | ចាស | ទេ |
|---|---|---|---|---|---|
| ដំណាក់ ទី២: កងដាក់ ក្រោមស្បែក ជាដែល | បញ្ជីសំនួរសំរាប់ មធ្យោបាយកងដាក់ ក្រោមស្បែក | ១ | កើតលឿង/ជំងឺថ្លើមធ្ងន់ធ្ងរ | | |
| | | ២ | ឈាមកកក្នុងសរសៃវ៉ែនជើង (សរសៃវ៉ែនជើងឡើងប៉ោងរឹង ខៀវ) ឬសួត | | |
| | | ៣ | មានដុំដោះមិនធម្មតា | | |
| | | ៤ | មានធ្លាក់ឈាមតាមទ្វារមាសដែលមិនដឹងមូលហេតុច្បាស់លាស់ | | |
| | | | បើឆ្លើយ (ចាស) នូវសំនួរណាមួយ ➜ ឈប់ អតិថិជនមិនអាចទទួលមធ្យោបាយពន្យារកំណើតដែលមានជាតិអ័រម៉ូនបានទេ | | |
| | | | បើឆ្លើយទេគ្រប់សំនួរទាំងអស់ ➜ សួរបន្តនូវសំនួរនៃមធ្យោបាយជាក់លាក់ខាងក្រោម | | |

| | | សូមគូស (✓) ក្នុងប្រអប់ហើយធ្វើតាមការណែនាំពីដើមរហូតដល់ចប់ | ចាស | ទេ |
|---|---|---|---|---|
| ដំណាក់ ទី១: កងដាក់ក្នុងស្បូនOK® | ១.១ | មានគភ៌ | | |
| | ១.២ | មានដៃគូរួមភេទច្រើន ឬដៃគូមានដៃគូរួមភេទច្រើន | | |
| | ១.៣ | ក្រោយសម្រាលកូនចន្លោះពី៤៨ម៉ោងទៅ៤សប្តាហ៍ | | |
| | ១.៤ | មានជំងឺមហារីកកន្សោមពង | | |
| | ១.៥ | មានជំងឺអេដស៍និងមិនប្រើថ្នាំប្រឆាំងមេរោគអេដស៍ ហើយមានស្ថានភាពសុខភាពទូទៅមិនល្អ | | |
| | ១.៦ | មានការប្រឈមមុខខ្ពស់នឹងជំងឺប្រមេះទឹកបាយ (Gonorrhea) និង ក្លាមីឌីយ៉ា | | |
| | ១.៧ | មានភាពស្លេកស្លាំង | | |
| | ១.៨ | សំរាលដោយវះកាត់យកកូនចេញបាន៦ខែ | | |
| | | **ការពិនិត្យអាងត្រគាគ:** | | |
| | ១.៩ | មានធ្លាក់ឈាមតាមទ្វារមាសខុសធម្មតា | | |
| | 2.0 | រលាកទ្វារមាស/ជំងឺរលាកអាងត្រគាក | | |
| | | បើឆ្លើយ (ចាស) នូវសំនួរណាមួយ ➜ ឈប់ | | |
| | | បើឆ្លើយ (ទេ) គ្រប់សំនួរទាំងអស់ ➜ កងដាក់ក្នុងស្បូនត្រូវបានផ្តល់ជូនអតិថិជនបាន | | |

# សម្ភារជំនួយសម្រាប់ការចាក់ថ្នាំជាថ្មីបន្ត

អតិថិជនគួរតែ ត្រូវបានកំណត់ពេលសម្រាប់ការចាក់ថ្នាំ DMPA ជារៀងរាល់១៣សប្តាហ៍។ យោងតាមសេចក្តីណែនាំរបស់អង្គការសុខភាពពិភពលោកឆ្នាំ២០០៨ ដែលជាអតិថិជនអាចចាក់ថ្នាំម្តងទៀតប្រសិនបើគាត់ត្រឡប់មកវិញក្នុងរយៈពេល២សប្តាហ៍មុន ឬ ៤សប្តាហ៍ក្រោយថ្ងៃណាត់ជួបរបស់នាងដោយមិនចាំបាច់ផ្ទៀងផ្ទាត់រកមើលការមានផ្ទៃពោះទេ។អតិថិជនដែល មកចាក់ថ្នាំម្តងទៀតក្រោយថ្ងៃណាត់ជួប អាចចាក់ជូនគាត់ផងដែរប្រសិនបើការពិនិត្យផ្ទៀងផ្ទាត់ថាគ្មានផ្ទៃពោះ។ អនុវត្តតាមជំហានដូចខាងក្រោមសម្រាប់អតិថិជនដែលវិលត្រឡប់មកចាក់ថ្នាំវិញ។ សម្រាប់អតិថិជនដែលចង់ចាក់ថ្នាំសារាប់លើកដំបូង ប្រើបញ្ជីសំណួរផ្ទៀងផ្ទាត់សម្រាប់អតិថិជនដែលចង់ផ្តួចផ្តើមប្រើថ្នាំចាក់ DMPA ( ឬ NET-EN ) ។

<u>ជំហានទី១</u> : សូមពិនិត្យមើលកំណត់ត្រារបស់អ្នកដើម្បីដឹងថាតើពេលណានាងទទួលការចាក់ថ្នាំចុងក្រោយរបស់នាងឬសាកសួរនាងថា តើនាងដឹងថានាងបានដឹងថ្ងៃណាត់ចាក់ម្តងទៀតដែរឬទេ ?

- ប្រសិនបើនាងត្រឡប់មកវិញក្នុងរយៈពេល២សប្តាហ៍មុន ឬហួស៤សប្តាហ៍ក្រោយថ្ងៃណាត់ជួប នាងនឹងស្ថិតនៅក្នុងរយៈពេលចំហរអាចទទួលថ្នាំចាក់បន្ត ➔ បន្តទៅជំហានទី២ (សូមមើលឧទាហរណ៍រយៈពេលចំហរអាចទទួលថ្នាំចាក់បន្ត)
- ប្រសិនបើនាងត្រឡប់មកហួសពី៤សប្តាហ៍ក្រោយថ្ងៃណាត់ជួប នាងត្រូវបានគេហាមឃាត់ នាងហួសរយៈពេលចំហរដើម្បីចាក់ថ្នាំបន្ត ➔ សូមមើលផ្នែកទី២នៃសម្ភារជំនួយការងារនេះ។

<u>ជំហានទី២</u> : សាកសួរអតិថិជនថា តើនាងត្រូវបានអ្នកផ្តល់សេវាប្រាប់ថាមានបញ្ហាសុខភាពថ្មីដែរឬទេ ?

- ប្រសិនបើគ្មានបញ្ហាទេ ➔ សូមបន្តទៅជំហានទី៣
- បញ្ហាសុខភាពថ្មីដែលតម្រូវឲ្យប្តូរមធ្យោបាយរួមមានឈឺក្បាលប្រកាំង ជាមួយនឹង aura (ប្រសិនបើមានការអភិវឌ្ឍឬកាន់តែអាក្រក់នៅពេលប្រើ DMPA ) ឬលក្ខខណ្ឌដែលបានពិពណ៌នាលើបញ្ជីត្រួតពិនិត្យសម្រាប់អតិថិជនដែលចង់ចាប់ផ្តើម DMPA or NET-EN ).
- ប្រសិនបើការបន្តត្រូវបានផាត់ចេញ ➔ ជួយគាត់ឲ្យជ្រើសរើសមធ្យោបាយមួយទៀត។ ប្រសិនបើសមស្របសម្រាប់ការចាក់ថ្នាំបន្ត ➔ សូមបន្តទៅជំហានទី៣

<u>ជំហានទី៣</u> :

- សូមផ្តល់ការធានាដល់អតិថិជនអំពីផលប៉ះរំខានបន្ទាប់បន្សំជាពិសេសការផ្លាស់ប្តូរឈាមរដូវ និងអាចបាត់ឈាមរដូវមួយរយៈដែលកើតមានជាញឹកញាប់ វាមិនប៉ះពាល់សុខភាពគាត់ទេ។ ប្រើពាក្យកាត់ NORMAL ដើម្បីរំលឹកនាងពីសារៈសំខាន់។ ប្រសិនបើអតិថិជនមិនមានការព្រួយបារម្ភទេ ➔ បន្តទៅជំហានទី ៤
- ប្រសិនបើអតិថិជនមានការព្រួយបារម្ភ ➔ គ្រប់គ្រងយោងទៅតាមអនុសាសន៍នៅក្នុងពិធីសារជាតិ។ ប្រសិនបើនាងចង់បន្តប្រើ DMPA ➔ បន្តទៅជំហានទី ៤ ។

<u>ជំហានទី៤</u> : ចាក់ថ្នាំបន្តឲ្យស្ត្រី

<u>ជំហានទី៥</u> : ប្រាប់អតិថិជនឲ្យប្រើស្រោមអនាម័យបន្ថែមទៅលើការចាក់ថ្នាំ DMPA ដើម្បីការពារកាមរោគ និងអេដស៍ ប្រសិនបើគាត់មានអារម្មណ៍ថាប្រឈមមុខក្នុងការឆ្លង។

<u>ជំហានទី៦</u> : ធ្វើការណាត់ជួបសម្រាប់ការចាក់លើកក្រោយ ១៣សប្តាហ៍ក្រោយថ្ងៃចាក់។

- លើកទឹកចិត្តនាងឲ្យមកចាក់ថ្នាំបន្តទាន់ពេល និងពិភាក្សាជាមួយអ្នកផ្តល់សេវាពេលដែលនាងមានសំណួរ ឬការព្រួយបារម្ភ។
- ណែនាំនាងឲ្យត្រឡប់មកវិញជានិច្ច ទោះបីនាងត្រឡប់មកយឺតពេលក៏ដោយ។

<u>ជំហានទី៧</u> : ប្រាប់អតិថិជនថាប្រសិនបើនាងលើស៤សប្តាហ៍ក្រោយថ្ងៃណាត់ជួប នាងគួរប្រើស្រោមអនាម័យ ឬតមការរួមភេទរហូតដល់ថ្ងៃដែលនាងអាចវិលត្រឡប់មក ចាក់ថ្នាំបន្តទៀត

**ប្រសិនបើអតិថិជនវិលត្រឡប់មកវិញលើសពី៤សប្តាហ៍ នាងមិនស្ថិតនៅក្នុងរយៈពេលចំហរដែលអាចចាក់ថ្នាំបន្តបានទេ។ អនុវត្តតាមការណែនាំដូចខាងក្រោម ៖**

- ធ្វើការវាយតម្លៃ ប្រសិនបើការវិលត្រឡប់វិញក្នុងរយៈពេលចំហរ ដែលអាចចាក់ថ្នាំបន្តបាននៅតែជាបញ្ហាពិភាក្សាពីជម្រើសមធ្យោបាយពន្យារកំណើតផ្សេងទៀតដែលអាចសមស្របសម្រាប់នាងផង។

## ប្រើបញ្ជីសម្រាប់រកមើលការមានផ្ទៃពោះដែលបានកែសម្រួល

ផ្ទៀងផ្ទាត់រកមើលការមានផ្ទៃពោះដោយសាកសួរអតិថិជននូវសំណួរដូចខាងក្រោម។ នៅពេលសាកសួរសំណួរអតិថិជនជំនួស <u>ថ្ងៃ x</u> ដោយថ្ងៃចុងក្រោយដែលណាត់ជួបចាក់ថ្នាំបន្ត(កំណត់ដោយរាប់៤សប្តាហ៍ ចាប់ពីថ្ងៃដែលណាត់ជួបចាក់ថ្នាំបន្ត)។ ប្រសិនបើអាចប្រើប្រតិទិនពេលពិភាក្សាជាមួយអតិថិជន។

- តើអ្នកមានតមការរួមភេទចាប់តាំងពីថ្ងៃ X ដែរឬទេ?
- តើអ្នកមានបានប្រើមធ្យោបាយពន្យារកំណើតដែលអាចទុកចិត្តបាន (ឧទាហរណ៍ស្រោមអនាម័យត្រឹមត្រូវទៀងទាត់ចាប់តាំងពីថ្ងៃ X មកដែរឬទេ?
- តើអ្នកមានកូនតូចអាយុតិចជាង៦ខែ បំបៅកូនដោយទឹកដោះម្តាយសុទ្ធ និងអ្នកមិនទាន់មានឈាមរដូវដែរឬទេ?
- តើអ្នកមានប្រើថ្នាំការពារកំណើតបន្ទាន់រាល់ពេលរួមភេទមិនបានការពារចាប់តាំងពីថ្ងៃ X មកដែរឬទេ?

ប្រសិនបើអតិថិជនឆ្លើយចាស សំណួរណាមួយខាងលើសូមត្រឡប់ទៅជំហានទី២ផ្នែកទី១នៃសម្ភារជំនួយនេះ។ ប្រសិនបើគ្មានល័ក្ខខ័ណ្ឌវេជ្ជសាស្ត្រហាមឃាត់ និងនាងចង់បន្តប្រើថ្នាំចាក់ សូមផ្តល់ថ្នាំចាក់ជូននាង និងណែនាំនាងឲ្យតមការរួមភេទ ឬប្រើស្រោមអនាម័យ៧ថ្ងៃ។

ប្រសិនបើនាងឆ្លើយទេគ្រប់សំណួរខាងលើ នោះការមានផ្ទៃពោះមិនអាចផាត់ចោលបានទេ ប្រើឧបករណ៍តេស្តពិនិត្យផ្ទៃពោះប្រសិនបើលទ្ធផលអវិជ្ជមាន ត្រឡប់ទៅជំហានទី២វិញ។ប្រសិនបើនាងមិនមានល័ក្ខខ័ណ្ឌវេជ្ជសាស្ត្រហាមឃាត់ (សមស្រប) និងចង់បន្តប្រើថ្នាំចាក់ ។សូមផ្តល់ថ្នាំចាក់ជូននាងជាថ្មីបន្ត និងណែនាំនាងឲ្យតមការរួមភេទ ឬប្រើស្រោមអនាម័យ៧ថ្ងៃ។ វិលត្រឡប់មកធ្វើតេស្តទឹកនោមម្តងទៀតក្នុងកំឡុងពេល៣ ទៅ ៤សប្តាហ៍។




Source: World Health Organization/Department of Reproductive Health and Research (WHO), Johns Hopkins Bloomberg School of Public Health/Center for Communication Programs/INFO Project (CCP). Family Planning: A Global Handbook for Providers. Baltimore, MD and Geneva: CCP and WHO, 2017 update.

Adapted with permission from FHI 360

# ការគ្រប់គ្រងការធ្លាក់ឈាម

| ការត្អូញត្អែរ | មធ្យោបាយ | ការគ្រប់គ្រង |
|---|---|---|
| **ធ្លាក់ឈាមខ្លាំង អូសបន្លាយ ឬធ្លាក់ឈាមមិនទៀងទាត់**<br>• ធ្លាក់ឈាមខ្លាំង អូសបន្លាយឬធ្លាក់ឈាមមិនទៀងទាត់ការធ្លាក់ឈាមមិនបានគ្រោងទុកនិងធ្លាក់ឈាមខ្លាំងអាចត្រូវបានបិទបាំងដោយសារការធ្លាក់ឈាមក្រោយសម្រាល និងក្រោយការរំលូតកូនការធ្លាក់ឈាមរដូវ។ ផ្តល់ជូនការធានាចំពោះស្ត្រី។ សម្រាប់ការបំបៅកូនដោយទឹកដោះម្តាយសម្រាប់ស្ត្រីក្រោយសម្រាលកូន ផ្តល់ការប្រឹក្សានៅលើការផ្លាស់ប្តូរដែលអាចកើតឡើង នៅពេលដែលនាងបញ្ឈប់ការបំបៅដោះកូនក៏សំខាន់ដែរ។<br>• ការហូរឈាមធ្ងន់ធ្ងរឬមិនធម្មតាក៏អាចជាសញ្ញានៃរោគស្ត្រី ដទៃទៀតផងដែរបញ្ហាដូចជាជំងឺមហារីកដុំស្ទួនឬការឆ្លងរោគ និងអាចត្រូវការធ្វើការបញ្ជូនទៅអ្នកឯកទេសសម្រាប់ការវាយតម្លៃបន្ថែម។<br>• ហូរឈាមខ្លាំងនៅតែបន្ត ដែលជាលទ្ធផលបណ្តាលឲ្យមានសញ្ញាស្លេកស្លាំងធ្ងន់ធ្ងរ (ឧទាហរណ៍ស្លេកស្លាំងភាពទន់ខ្សោយ) ពិចារណាពីការផ្លាស់ប្តូរមធ្យោបាយជាមួយនឹងការយល់ព្រមរបស់ស្ត្រី។<br>• ប្រសិនបើស្ត្រីតម្រូវការចាក់បញ្ចូលឈាមដើម្បីព្យាបាលការហូរឈាមធ្ងន់ធ្ងរ:<br>** បញ្ជូនស្ត្រីទៅមណ្ឌលបញ្ជូនរបស់អ្នក*<br>** ជូនដំណឹងដល់ PSI* | ស៊ី អូ ស៊ី / ភី អូ ភី | **ការធ្លាក់ឈាមមិនទៀងទាត់នៅចន្លោះវដ្តឈាមរដូវជាញឹកញាប់អាចកើតមានឡើងក្នុងកំឡុងពេល៣ខែដំបូង និងអាចមានទាក់ទងនឹងការដែលខកខានលេបថ្នាំ**<br>• ធានាប្រាប់ស្ត្រីថាទាំងនេះនឹងមានភាពប្រសើរឡើងវិញ ពេលក្រោយ និងជាការកំរណាស់ដែលប៉ះពាល់ជាព្រឹត្តិការណ៍អាក្រក់ដល់សុខភាព។<br>• លើកទឹកចិត្តស្ត្រីឲ្យលេបថ្នាំគ្រប់ពេលវេលា និងកុំខកខានឲ្យសោះ។<br>• ប្រសិនបើស្ត្រីមានការព្រួយបារម្ភហើយមានរយៈពេលច្រើនជាង៣ខែបានកន្លងផុតទៅពិចារណាលើការប្រើថ្នាំដែលមានកម្រិតអ័រម៉ូនprogestin ផ្សេងទៀត ឬមានដូសទាប។<br>• ប្រសិនបើស្ត្រីកំពុងប្រើ ភី អូ ភី និងមានភាពសមស្របអាចប្រើ ស៊ី អូ ស៊ី អាចពិចារណាប្តូរមធ្យោបាយ។<br>• ប្រសិនបើសិនជាស្ត្រីមិនអាចទទួលយកបាននឹងការធ្លាក់ឈាម និងចង់ឈប់ប្រើ ផ្តល់ប្រឹក្សាពីមធ្យោបាយពន្យារកំណើតផ្សេងទៀត និងផ្តល់ឲ្យមធ្យោបាយតាមជម្រើសរបស់នាង។ |
| | មធ្យោបាយផ្សេងទៀត | **ថ្នាំចាក់:** ជារឿយៗការធ្លាក់ឈាម អាចបាត់ទៅវិញនៅពេលបន្តការចាក់ថ្នាំ DMPA **កងដាក់ក្រោមស្បែក** NXT ការធ្លាក់ឈាមចន្លោះវដ្ត ឈាមរដូវអាចកើតមានក្នុងកំឡុងពេល៣ខែដំបូង។ **ឡាដែល** ការប្រែប្រួលការធ្លាក់ឈាម អាចកើតមានបន្តពី៦ ទៅ ១២ ខែ។ **កងដាក់ក្នុងស្បូន :** ការធ្លាក់ឈាមនៅចន្លោះវដ្តឈាមរដូវ និងប្រសើរឡើងវិញ ថយចុះ ឬបាត់ទៅវិញនៅ២ ទៅ៣ខែក្រោយពេលដាក់កង។<br>• ធានាដល់ស្ត្រីថាជាធម្មតា វំលឹកឡើងវិញពី (NORMAL) លើកទឹកចិត្តនាងឲ្យបន្តការប្រើមធ្យោបាយការរង់ចាំមើលជាទូទៅមានប្រសិទ្ធភាព។<br>• ប្រសិនបើស្ត្រីចង់ព្យាបាលការធ្លាក់ឈាម: ផ្តល់ថ្នាំ NSAIDS ដូចជា Ibuprofen 400 -800 mg ៣គ្រាប់ ក្នុងមួយថ្ងៃរយៈពេល៥ថ្ងៃ ឬTranexamic acid 500-1500 mg ៣គ្រាប់ក្នុងមួយថ្ងៃរយៈពេល៥ថ្ងៃពេលដែលចាប់ផ្តើមធ្លាក់ឈាម។<br>• ប្រសិនបើមិនមានប្រសិទ្ធភាព ចាប់ផ្តើមប្រើស៊ី អូ ស៊ី ប្រសិនបើសមស្របល័ក្ខខ័ណ្ឌវេជ្ជសាស្ត្រជាមួយមធ្យោបាយនេះ ប្រើពី១ទៅ៣បន្ទះអាចធ្វើឲ្យការធ្លាក់ឈាមមានភាពប្រសើរឡើង។<br>• ប្រសិនជាស្ត្រីមិនអាចទទួលយកបាននូវការធ្លាក់ឈាមនិងចង់ឈប់ប្រើ ផ្តល់ប្រឹក្សាពីមធ្យោបាយពន្យារកំណើតផ្សេងទៀត និងផ្តល់មធ្យោបាយជូនតាមជម្រើសរបស់នាង។<br>• ប្រសិនស្ត្រីបារម្ភពីការបាត់ឈាមរដូវសូមផ្តល់នូវជាតិដែកនិងការលើកទឹកចិត្តការ ផ្តល់អាហារបំប៉នជាមួយអាហារសំបូរជាតិដែក (សាច់ ស្លឹកបៃតងចាស់ បន្លែ ពពួកធញ្ញជាតិ) |
| បាត់ឈាមរដូវ | ថ្នាំចាក់ | • ធានាដល់ស្ត្រីថាវាជាធម្មតា មិនប៉ះពាល់ដល់ភាពវិលត្រឡប់មកមានកូនវិញទេ (រំលឹកឡើងវិញពី NORMAL)<br>• នៅពេលសមស្រប ចូលធ្វើការផាត់ចោលការមានផ្ទៃពោះដោយសាកសួរប្រវត្តិ ឬការធ្វើតេស្តដែលអាចរកបាន។ • ប្រសិនបើស្ត្រីព្រួយបារម្ភខ្លាំងពីការបាត់ឈាមរដូវនាងចង់ឈប់ប្រើថ្នាំចាក់ ផ្តល់ប្រឹក្សាពីមធ្យោបាយពន្យារកំណើតផ្សេងទៀត រួមទាំងការរំពឹងទុកប្រែប្រួលការធ្លាក់ឈាមនិងផ្តល់មធ្យោបាយដែលនាងជ្រើសរើស ។ |

# ការគ្រប់គ្រងបញ្ហាសុខភាពផ្សេងៗ

| | | | | |
|---|---|---|---|---|
| ឈឺក្បាល / ឈឺក្បាលប្រកាំង<br><br>សំគាល់: ស្ត្រីឈឺក្បាលអាចប្រើកងដាក់ក្នុងស្បូនបាន | ស៊ី អូ ស៊ី | • សាកសួរនាងប្រសិនបើមានការផ្លាស់ប្តូរការធ្លាក់ឈាមតាំងពីចាប់ផ្តើមប្រើមធ្យោបាយ | ប្រសិនបើឈឺក្បាលតិចតួច ឬមធ្យម (មិនឈឺក្បាលប្រកាំង)<br>• ព្យាបាលជាមួយថ្នាំបំបាត់ការឈឺចាប់ និងធានាអះអាង។<br>• វាយតម្លៃឡើងវិញ១ខែក្រោយ។<br>• ប្រសិនស្ត្រីមានអារម្មណ៍មិនសុខស្រួល និងទទួចលើការផ្លាស់ប្តូរមធ្យោបាយ ផ្តល់ប្រឹក្សាពីមធ្យោបាយពន្យារកំណើតផ្សេងទៀត និងផ្តល់មធ្យោបាយដែលនាងជ្រើសរើស។ | ប្រសិនឈឺក្បាលប្រកាំង គ្មាន aura និងអាយុតិចជាង៣៥ឆ្នាំ:<br>• អាយុតិចជាង៣៥ឆ្នាំ ពិភាក្សាពីផលចំណេញ ភាពប្រឈមមុខក្នុងការបន្តប្រើមធ្យោបាយ (WHO MEC Class3)<br>• ប្រសិនស្ត្រីស្នើសុំជួយនាង ឲ្យជ្រើសរើសមធ្យោបាយផ្សេងទៀត<br>ប្រសិនបើមានឈឺក្បាលប្រកាំងដោយមិនមាន aura មានអាយុលើសពី៣៥ឆ្នាំ ឬឈឺក្បាលប្រកាំងជាមួយការមាន aura, មានស្ពឹក ឬឈឺចាប់, ការបាត់បង់ការនិយាយ ការផ្លាស់ប្តូរ ការមើលឃើញ ឬព្រិលភ្នែក:<br>• បញ្ឈប់ការប្រើមធ្យោបាយ និងជួយអតិថិជនឲ្យជ្រើសរើសមធ្យោបាយដែលមិនមានអ័រម៉ូន។ |
| | ភី អូ ភី ថ្នាំចាក់, កងដាក់ក្រោមស្បែក | • សាកសួរនាងប្រសិនបើមានការផ្លាស់ប្តូរការធ្លាក់ឈាមតាំងពីចាប់ផ្តើមប្រើមធ្យោបាយ | ប្រសិនបើឈឺក្បាលតិចតួច ឬមធ្យម (មិនឈឺក្បាលប្រកាំង)<br>• ព្យាបាលជាមួយថ្នាំបំបាត់ការឈឺចាប់ និងធានាអះអាង។<br>• វាយតម្លៃឡើងវិញ១ខែក្រោយ។<br>• ប្រសិនបើស្ត្រីមានអារម្មណ៍មិនសុខស្រួល និងទទួចលើការផ្លាស់ប្តូរមធ្យោបាយផ្តល់ប្រឹក្សាពីមធ្យោបាយពន្យារកំណើតផ្សេងទៀត និងផ្តល់មធ្យោបាយដែលនាងជ្រើសរើស។ | ប្រសិនបើឈឺក្បាលប្រកាំង និងបន្តឬអមដោយ aura, និងមានស្ពឹកឬឈឺចាប់, ការបាត់បង់ការនិយាយ ការផ្លាស់ប្តូរការមើលឃើញ, ឬព្រិលភ្នែក :<br>• ផ្តល់ប្រឹក្សាពីផលចំណេញ ភាពប្រឈមមុខក្នុងការបន្តប្រើមធ្យោបាយ (WHO MEC Class3)<br>• ប្រសិនបើស្ត្រីស្នើសុំជួយនាងឲ្យជ្រើសរើសមធ្យោបាយផ្សេងទៀត។ |
| សម្ពាធឈាមខ្ពស់<br><br>សំគាល់: កងដាក់ក្នុងស្បូនអាចប្រើបានសម្រាប់ស្ត្រីដែលមានសម្ពាធឈាមខ្ពស់ | ស៊ី អូ ស៊ី | សម្ពាធឈាមលើសពី ១៤០/៩០ mm Hg ប៉ុន្តែតិចជា ១៦០/១០០ mm Hg<br>• ផ្តល់ប្រឹក្សាពីផលចំណេញ ភាពប្រឈមមុខក្នុងការបន្តប្រើមធ្យោបាយ (WHO MEC Class3)<br>• ប្រសិនបើស្ត្រីស្នើសុំជួយនាងឲ្យជ្រើសរើសមធ្យោបាយផ្សេងទៀត។ | | សម្ពាធឈាមលើសពី ១៦០/១០០ mm Hg<br>• បញ្ឈប់ការប្រើមធ្យោបាយ និងជួយអតិថិជនឲ្យជ្រើសរើសមធ្យោបាយដែលមិនមានអ័រម៉ូន។ |
| | ភី អូ ភី ថ្នាំចាក់ កងដាក់ក្រោមស្បែក | សម្រាប់ ភី អូ ភី ថ្នាំចាក់ និងកងដាក់ក្រោមស្បែកសម្ពាធឈាមលើសពី ១៤០/៩០ mm Hg ប៉ុន្តែតិចជា ១៦០/១០០ mm Hg<br>• ផ្តល់ប្រឹក្សាដល់ស្ត្រី គឺមិនតម្រូវផ្លាស់ប្តូរមធ្យោបាយលើកលែងស្នើសុំប្តូរ។<br>• ប្រសិនបើស្ត្រីស្នើសុំជួយនាងឲ្យជ្រើសរើសមធ្យោបាយផ្សេងទៀត ប្រាប់នាងថាសម្ពាធឈាមខ្ពស់អាចធូរស្រាលវិញ១ទៅ៣ខែក្រោយ។<br>• វាស់សម្ពាធឈាមរៀងរាល់ខែ បញ្ជាក់ច្បាស់ថា វាត្រឡប់មកភាពធម្មតាវិញ ។<br>• ប្រសិនបើលើសពី៣ខែហើយ វាមិនត្រឡប់មកភាពធម្មតាវិញទេ បញ្ជូនទៅវាយតម្លៃបន្ថែម។ | | សម្រាប់ថ្នាំចាក់ សម្ពាធឈាមលើសពី ១៦០/១០០ mm Hg<br>• ផ្តល់ប្រឹក្សាពីផលចំណេញ ភាពប្រឈមមុខក្នុងការបន្តប្រើមធ្យោបាយ (WHO MEC Class3)<br>• ប្រសិនបើស្ត្រីស្នើសុំជួយនាងឲ្យជ្រើសរើសមធ្យោបាយផ្សេងទៀត។ |

# សម្ភារជំនួយសម្រាប់រកមើលការមានផ្ទៃពោះមុនការចាប់ផ្តើមប្រើមធ្យោបាយពន្យារកំណើត

ផ្ទៀងផ្ទាត់ការធ្លាក់ឈាមរដូវអតិថិជន និងជ្រើសរើសមធ្យោបាយណាមួយដូចមានជម្រើស និងតាមការណែនាំខាងក្រោម

## អតិថិជនមិនទាន់មានឈាមរដូវ (ក្រោយសម្រាល ឬប្រភេទផ្សេងទៀត)

| កងដាក់ក្រោមស្បែក,ថ្នាំគ្រាប់ ,ring, ថ្នាំចាក់ ឬ Patch | កងដាក់ក្នុងស្បូន (Copper or LNG) |
|---|---|

**ប្រើបញ្ជីសំណួររកមើលការមានផ្ទៃពោះ** [1]
ការមានផ្ទៃពោះត្រូវបានផាត់ចោលៈ ផ្តល់មធ្យោបាយពន្យារកំណើតជូនស្ត្រី

ការមានផ្ទៃពោះមិនអាចផាត់ចោលបានៈ ប្រើតេស្តពិនិត្យរកមើលការមានផ្ទៃពោះ (តេស្តទឹកនោម)

| កងដាក់ក្រោមស្បែក,ថ្នាំគ្រាប់ ,ring, ថ្នាំចាក់ ឬ Patch | កងដាក់ក្នុងស្បូន (Copper or LNG) |
|---|---|
| លទ្ធផលអវិជ្ជមាន (ឬមិនមានតេស្តអាចរកបានភ្លាមៗ): ផ្តល់មធ្យោបាយពន្យារកំណើតជូនស្ត្រីពេលនេះ។ ណាត់ជួបធ្វើតេស្តម្តងទៀត៣ ទៅ ៤សប្តាហ៍ក្រោយ។ | លទ្ធផលអវិជ្ជមាន (ឬមិនមានតេស្តអាចរកបានភ្លាមៗ): ណែនាំឲ្យស្ត្រីប្រើស៊ី អូ ស៊ី ថ្នាំចាក់ DMPA ឬស្រោមអនាម័យណាត់ជួបធ្វើតេស្តម្តងទៀត៣ ទៅ ៤សប្តាហ៍ក្រោយ។ តេស្ត លើកទី២លទ្ធផលអវិជ្ជមានផ្តល់កងដាក់ក្នុងស្បូន។ |

1.មើលទំព័រ បញ្ជីសំណួររកមើលការមានផ្ទៃពោះ

2. សម្រាប់កងដាក់ក្រោមស្បែក , ផ្តល់ប្រឹក្សាអំពីតម្រូវឲ្យដកកងចេញប្រសិនបើតេស្តទឹកនោមមានផ្ទៃពោះត្រូវបានបញ្ជាក់ និងនាងមានបំណងរក្សាទុកការមានផ្ទៃពោះ។

ក្នុងករណីការមានផ្ទៃពោះមិនអាចផាត់ចោលបាន ផ្តល់មធ្យោបាយការពារកំណើតបន្ទាន់ប្រសិនបើនាងរួមភេទមិនបានការពារក្នុងកំឡុង ៧២ម៉ោង។

ផ្តល់ប្រឹក្សាឲ្យស្ត្រីវិលត្រឡប់មកវិញគ្រប់ពេលដែលពួកគេមានហេតុផលថាសង្ស័យមានផ្ទៃពោះ (ឧទាហរណ៍បាត់ឈាមរដូវ)

Adapted with permission from FHI 360.

## អតិថិជនមានឈាមរដូវទៀងទាត់ចន្លោះពេល២ខែ (មានធ្លាក់ឈាមរដូវប្រចាំខែ)

| កងដាក់ក្រោមស្បែក ថ្នាំគ្រាប់, ring, ថ្នាំចាក់ ឬ Patch | កងដាក់ក្នុងស្បូន (Copper or LNG) |
|---|---|

**ប្រើបញ្ជីសំណួររកមើលការមានផ្ទៃពោះ** [1]
ការមានផ្ទៃពោះត្រូវបានផាត់ចោល ផ្តល់មធ្យោបាយជូនស្ត្រី
**កុំប្រើតេស្តទឹកនោម (ក្នុងករណីភាគច្រើនវាឆាប់ពេកសម្រាប់ឲ្យមានប្រសិទ្ធភាព)**

| កងដាក់ក្រោមស្បែក ថ្នាំគ្រាប់, ring, ថ្នាំចាក់ ឬ Patch | កងដាក់ក្នុងស្បូន (Copper or LNG) |
|---|---|
| ការមានផ្ទៃពោះមិនអាចផាត់ចោលបានៈ ផ្តល់មធ្យោបាយពន្យារកំណើតជូនស្ត្រីពេលនេះ។<br><br>ណាត់ជួបធ្វើតេស្តម្តងទៀតប្រសិនបើពន្យារពេលធ្លាក់ឈាមរដូវខែបន្ទាប់។ | ការមានផ្ទៃពោះមិនអាចផាត់ចោលបាន:មិនផ្តល់មធ្យោបាយពន្យារកំណើតជូនស្ត្រីទេ។<br><br>ណែនាំស្ត្រីឲ្យត្រឡប់វិញក្នុងអំឡុង៧ថ្ងៃនៃវដ្តឈាមរដូវលើកក្រោយសម្រាប់ LNG ឬអំឡុង១២ថ្ងៃសម្រាប់ Copper IUD. ប៉ុន្តែប្រើជាបណ្តោះអាសន្ន ស៊ី អូ ស៊ី ថ្នាំចាក់ DMPA ឬស្រោមអនាម័យ ឬតមការរួមភេទ។ ណាត់ជួបធ្វើតេស្តម្តងទៀតប្រសិនបើពន្យារពេលធ្លាក់ឈាមរដូវខែបន្ទាប់។ |

* **ប្រសិនបើអតិថិជនបង្ហាញខ្លួនពេលមិនទាន់មានឈាមរដូវ ប្រើតេស្តទឹកនោមដើម្បីផាត់ចោលការមានផ្ទៃពោះ។** បើប្រើតេស្តរកមើលការមានផ្ទៃពោះ hightly sensitive (ឧទាហរណ៍ 25 mIU/ml និងលទ្ធផលអវិជ្ជមានផ្តល់មធ្យោបាយពន្យារកំណើតជូនស្ត្រីតាមការចង់បានរបស់នាង។

បើប្រើតេស្តរកមើលការមានផ្ទៃពោះ lower sensitive (ឧទាហរណ៍ 50 mIU/ml និងលទ្ធផលអវិជ្ជមានក្នុងអំឡុងពេលបាត់ឈាមរដូវ រង់ចាំយ៉ាងហោចណាស់១០ថ្ងៃក្រោយថ្ងៃរំពឹងទុកថាធ្លាក់ឈាមរដូវ និងធ្វើតេស្តម្តងទៀត។ ណែនាំស្ត្រីឲ្យប្រើស្រោមអនាម័យជាបណ្តោះអាសន្ន

*ប្រសិនបើលទ្ធផលតេស្តនៅតែអវិជ្ជមាន ផ្តល់មធ្យោបាយពន្យារកំណើតជូនស្ត្រីតាមការចង់បានរបស់នាង។ ប្រសិនបើតេស្ត sensitive មិនដាក់លាក់សន្មត់ថាតេស្ត lower sensitive។*

# តើត្រូវប្រាកដថាអតិថិជនមិនមានផ្ទៃពោះតាមរបៀបណា: ប្រវត្តិអតិថិជន

សាកសួរសំណួរអតិថិជនពី១ដល់៦ ។ នៅពេលដែលនាងឆ្លើយ (ចាស) នូវសំណួរណាមួយ បញ្ឈប់ការសួរ និងធ្វើតាមការណែនាំ។

| | សូមគូស (✓) ក្នុងប្រអប់ហើយធ្វើតាមការណែនាំពីដើមរហូតដល់ចប់ | ចាស | ទេ |
|---|---|---|---|
| បញ្ជីសំនួរដើម្បីដឹងថាមានផ្ទៃពោះ | តើរដូវចុងក្រោយរបស់អ្នកបានចាប់ផ្តើមមានក្នុងកំឡុង៧ថ្ងៃមុន( ឬកំឡុង១២ថ្ងៃមុន ប្រសិនបើអ្នកមានផែនការប្រើកងដាក់ក្នុងស្បូន ) ដែរឬទេ ? | | |
| | តើអ្នកមានកូនតូចអាយុតិចជាង៦ខែកំពុងបំបៅកូនដោយទឹកដោះម្តាយពេញលេញ ឬជិតពេញលេញ និងមិនទាន់មានឈាមរដូវនៅឡើយ ចាប់តាំងពីអ្នកសម្រាលកូនដែរឬទេ ? | | |
| | តើអ្នកតម្អូមភេទតាំងពីអ្នកមានឈាមរដូវលើកចុងក្រោយ ឬតាំងពីសម្រាលកូនរួចដែរឬទេ ? | | |
| | តើអ្នកទើបសម្រាលកូនហើយបាន៤សប្តាហ៍ដែរឬទេ ? | | |
| | តើអ្នកមានរលូតឬរំលូតកូនក្នុងរយៈពេល៧ថ្ងៃមុន( ឬកំឡុង១២ថ្ងៃមុនប្រសិនបើអ្នកមានផែនការប្រើកងដាក់ក្នុងស្បូន ) ដែរឬទេ ? | | |
| | តើអ្នកកំពុងប្រើមធ្យោបាយពន្យារកំណើតជាប់លាប់ និងត្រឹមត្រូវដែរឬទេ ? | | |
| | គ្មានសញ្ញានៃការមានផ្ទៃពោះទេ | ឆ្លើយ (ចាស) ១ ឬច្រើនហើយ | ឆ្លើយ "ទេ" ទាំងអស់ |
| | អ្នកអាចផ្តល់មធ្យោបាយពន្យារកំណើតឲអតិថិជនបាន | ឈប់: ការមានផ្ទៃពោះមិនអាចផាត់ចោលបានទេអតិថិជនគួររង់ចាំការមានឈាមរដូវបន្ទាប់ឬប្រើឧបករណ៍តេស្តពិនិត្យផ្ទៃពោះ។ | |

ប្រសិនបើអតិថិជន ឆ្លើយ**ទេ គ្រប់សំណួរទាំងអស់**, ការមានផ្ទៃពោះមិនអាចផាត់ចោលបានទេតាមរយៈការប្រើបញ្ជីសំណួរ។

ប្រសិនបើអតិថិជនឆ្លើយ**ចាសយ៉ាងហោចណាស់សំណួរមួយ** ហេតុផលនេះ បញ្ជាក់ថាគ្មានផ្ទៃពោះ

Adapted with permission from FHI 360.

